


# ករណីយកិច្ច នៃកំណត់ការចងចាំ

មានមតិពីរ ប្រទល់គ្នា អំពី ការសម្លាប់មហាជន ដែលបាន ប្រព្រឹត្តិដោយ របបខ្មែរក្រហម នៅទស្សវត្សរ៍ ៧០។ មតិ ទី១ យល់ឃើញថា អំពើឃាតកម្មនេះ មានតុលាការចម្រុះ ខ្មែរ-អន្តរជាតិ កំពុងរកយុត្តិធម៌ ជូនដល់អ្នករងគ្រោះ។ ហើយ អតីតអ្នកដឹកនាំសំខាន់ៗ ត្រូវបានតុលាការ កាត់ក្តីដាក់ទោស ហើយ កំពុងបន្តស្រាវជ្រាវ រកបុគ្គល ដែលមានពាក់ព័ន្ធនឹងឃាតកម្មនោះ។ ម្លោះហើយ យុត្តិធម៌ ត្រូវបានធ្វើរួចហើយ, ដូច្នេះ ជនរងគ្រោះទាំងឡាយ ត្រូវបញ្ចប់ នូវកំហឹងនឹង អតីតកាលដ៏ជូរចត់ ហើយនាំគ្នាគិតអំពីអនាគតកាល ដើម្បី ខ្លួនឯងផង និង ប្រជាជាតិផង។ តែ មតិ ទី២ យល់ឃើញថា យុត្តិធម៌ គឺជាការចាំបាច់ពិត តែវា មិនគ្រប់គ្រាន់ សំរាប់ ដោះស្រាយ ដោយសីលធម៌ នូវការសម្លាប់មហាជន ដែលជា ព្រឹត្តិការណ៏ មានទំហំ នៃ មនុស្សជាតិ។ ដូច្នេះ ប្រជាជាតិខ្មែរ ត្រូវមាន ករណីយកិច្ច នៃ កំណត់ការចងចាំបន្ថែម ដើម្បី រំលឹកដល់វិញ្ញានខណ្ឌ នៃជនរងគ្រោះ ដែលបានបាត់បង់ជីវិត និង ដាស់សតិសម្បជញ្ញៈ ដល់ខ្មែរបច្ចុប្បន្ន ទោះបី ជាជនរងគ្រោះក្តី មិនរងគ្រោះក្តី អោយ រវាំងលើ អំពើ នៃការសម្លាប់មហាជននោះ កុំអោយ វាអាចនឹង កើតមានម្តងទៀត។ ម្យ៉ាងមួយទៀត ករណីយកិច្ច នៃកំណត់ការចងចាំ វាជា សតិរស់រវើង នៅក្នុងព្រលឹងជាតិខ្មែរ មាន

កំហឹង (indignation) នឹង គ្រប់អំពើ អន្យាយ្យធម៌ ដែលធ្លាប់កើតមាន, កំពុងកើតមាន និង នឹងអាចកើតមាន នៅក្នុងសង្គមខ្មែរ។ កំហឹងនេះឯង ដែលជាចរន្ត នៃប្រវត្តិសាស្ត្រ ដែលនាំមនុស្សជាតិ ដើរទៅរក ការរីកចំរើន នៅក្នុងសេចក្តីថ្លៃថ្នូរ។ ស្រុកខ្មែរសព្វថ្ងៃ, ស្ថិតនៅក្នុង ស្ថានភាពសន្តិភាព មិនទៀងមួយ, ទទួលនូវការគំរាមកំហែងពីអំពើឃោរឃៅគ្រប់បែបយ៉ាងកើតចេញពី បរិបទនយោបាយហិង្សា, ការរៀបចំសង្គម និងសេដ្ឋកិច្ចជាតិ, ចរភាព នៃអន្តោប្រវេសន៏ នៃ យួននិករ[1] មកក្នុងស្រុកខ្មែរ។ ការគំរាមកំហែងនេះ ជារងើកភ្លើង អាចនឹងឆេះ នៅពេលណាមួយវាជួបប្រទះនឹងខ្យល់ ហើយខ្យល់នោះ វាកំពុងតែពួនខ្លួន នៅក្នុង អកុសលខ្មែរ (le mal khmer) ហើយសព្វថ្ងៃនេះ អកុសល និង កុសល វាច្របូកច្របល់គ្នា ដែលនាំអោយ ប៉ះពាល់ផ្ទាល់ដល់ និច្ច័យ នៃសីលធម៌ (le sens de la morale) នៅក្នុងសង្គមខ្មែរ។ តួយ៉ាង ទោះបីនៅស្រុកខ្មែរ មានសារមន្ទីរ សំរាប់បង្ហាញ នូវអំពើឃោរឃៅ របស់ពួកខ្មែរក្រហម, ឯកសារ ស្វែងរកការពិត អំពីឃាតកម្មមហាជន និង តុលាការចម្រុះ ខ្មែរ-អន្តរជាតិ ដើម្បី កាត់ទោស ចារីធំៗ នៃឃាតកម្មតែ ក្នុងវិស័យ សិទ្ធិមនុស្ស ទទួលការប្រមាថគ្រប់បែបយ៉ាង ពីសំណាក់អាជ្ញាធរ។ ការរំលោភសិទ្ធិនេះ ក្នុងនិច្ច័យ នៃមនុស្សជាតិ គឺទុកជា វិច្ឆេទកម្ម ប្រឆាំងនឹងប្រជាពលរដ្ឋ។ ដូចយ៉ាងពួកខ្មែរក្រហម ប្រើមធ្យោបាយ សម្លាប់មហាជន ដើម្បីផ្ទើ

---

[1] La foule ou la masse des Vietnamiens.

បន្សុទ្ធកម្ម[2] សង្គម, រីឯ របបដឹកនាំបច្ចុប្បន្ន វិញ សម្លាប់ និង
ចាប់ដាក់គុក អ្នកប្រឆាំង ដើម្បី ពង្រឹង អំណាចផ្តាច់ការ។
មែនពិត, តាមសតិបញ្ញា គេមិនអាចប្រៀបធៀបទំហំ នូវ
ឧក្រិដ្ឋកម្ម ប្រព្រឹត្តិ ដោយពួកខ្មែរក្រហម នឹង របបដឹកនាំ
បច្ចុប្បន្ន តែគេមើលឃើញ នូវដំណូច នៃគោលការណ៍ គឺ ឧក្រិដ្ឋ
កម្ម ប្រឆាំងនឹងមនុស្សជាតិ ដើម្បី ពង្រឹងអំណាច។ ពួកខ្មែរ
ក្រហម ធ្វើតាមគំរូយួនកុម្មុយនិស្ត រីឯ របបដឹកនាំសព្វថ្ងៃ ធ្វើ
តាមបញ្ជាយួន : តែ លទ្ធផល វាដូចគ្នា គឺធ្វើអោយប្រជាជាតិ
ខ្មែរ ចុះខ្សោយ ដោយហុចចំណេញអោយមហាយៀកណាម។ តែ
ការដែលត្រូវបារម្ភ ខ្លាំង គឺ ប្រជាពលរដ្ឋខ្មែរបច្ចុប្បន្ន ហាក់
បីដូចជា ប្រងើយកន្តើយនឹង បាតុភូតដ៏ចង្រៃនេះ ហើយ ព្រម
ទទួល ដើម្បី រស់ៗមានជីវិត។ ត្រូវដឹងថា វាពុំអាចមានប្រជា
ពលរដ្ឋល្អ នៅក្នុងប្រទេសមួយ ដែលមាន សង្គមមិនល្អនោះ
ឡើយ ព្រោះមនុស្ស ជាចារី និង ជាផលា ព្រមគ្នា នៃសង្គម។ ការ
ណ៏នេះ ដែលនាំឲម៉ាស៊ីន នៃការគាបគៀត ដ៏ហិង្សាបច្ចុប្បន្ន
ដែលមានប្រភពចេញពី របបខ្មែរក្រហមបន្តដើរ ដើម្បីបង្ក្រាប
នូវ សេរីភាព នៃពលរដ្ឋ និង លុបលទ្ធិប្រជាធិបតេយ្យ ដែលជា
លទ្ធវត្ថុ (éléments acquis) របស់ប្រជាពលរដ្ឋខ្មែរ នៅក្នុងក្រប
ខណ្ឌ នៃកិច្ចព្រមព្រៀងសន្តិភាព ២៣ តុលា ឆ្នាំ ១៩៩១ និង រដ្ឋ
ធម្មនុញ្ញ ១៩៩៣។ ការដើរថយក្រោយ នៃលទ្ធិប្រជាធិបតេយ្យ
នៅស្រុកខ្មែរ វាបញ្ជាក់បង្ហាញ នូវ អវត្តមាន នៃ ករណីយកិច្ច

---

[2] Purification.

នៃកំណត់ការចងចាំ ជាចំណេះយល់ដឹង[3] អំពីព្រឹត្តិការណ៍ ដែលបានកើតមានឡើង ដែលទុកជា ករណីយកិច្ចដាច់ខាត ពុំនោះសោធ វាគ្រាន់តែជាអនុស្សាវរីយ៍ របស់បុគ្គល គ្រាន់តែរក្សាទុកនៅក្នុងសតិហើយ ជួនកាល វានឹកឃើញ រប៉ាត់រប៉ាយនៅក្នុងអារម្មណ៍គ្រៀវក្រោធ តែភ្លេចអស់ នូវនិច្ច័យពិតរបស់វា។

ការខុសគ្នា រវាង ករណីយកិច្ច នៃកំណត់ការចងចាំ នឹងអនុស្សាវរីយ៍ គឺ កំណត់ការចងចាំ ជាការអប់រំ សីលធម៌ នៃមនុស្សជាតិ ដើម្បី ទប់នឹងអំពើអសីលធម៌ ដែលធ្លាប់បានកើតឡើង ដែលនាំបំផ្លាញ ដល់មនុស្សជាតិ។ ដូច្នេះ វាជា មេរៀន ដកស្រង់ចេញពីការពិសោធ ពីអតិតកាល សំរាប់យកមកធ្វើការកែលំអក្នុងបច្ចុប្បន្នកាល។ ជាកំណត់ចងចាំ រួម និង រស់រវើក ប្រកាសប្រាប់ ជាការរំលឹក ដល់សាធារណជន ថា នៅទីកន្លែងមួយ ក្នុងពេលវេលា ព្យាកត-មួយ មានកើតអំពើព្រៃផ្សៃមួយ ប្រព្រឹត្តដោយមនុស្សម្នាក់, ក្រុមមួយ, អាជ្ញាធរ នៃរដ្ឋមួយ ដែលបណ្តាលអោយមានមនុស្សគ្មានកំហុស ស្លាប់រង្គាល ដោយអយុត្តិធម៌ ជាទីបំផុត។ ដូច្នេះ វាអាចចាត់ទុកជា ការចោទដោយសាធារណជនក្នុងនាម នៃសង្គមមនុស្ស លើអំពើទុយ៍ស។ អំពើនោះ បានកើតមានឡើងពិតនៅស្រុកខ្មែរ ចាប់ពីថ្ងៃទី ១៧ មេសា ឆ្នាំ ១៩៧៥ ដែលវានាំអោយមានកម្មវិបាក ដល់ប្រជាពលរដ្ឋខ្មែររហូតមកដល់សព្វថ្ងៃនេះ។ សំនួរសួរថា តើពួកអ្នកដឹកនាំខ្មែរ

[3] Connaissance raisonnée.

សព្វថ្ងៃ គាត់ទាញយកជាប្រយោជន៍ ពីអំពើ ឃាតកម្មមហាជន ពីអតីតកាល ដើម្បី ជៀស ផ្លោយប្រព្រឹត្តិ អំពើនោះ បានដែរ ឬទេ ? សំនួរនេះ វាពិបាកនឹងឆ្លើយណាស់ បើគ្មាន លទ្ធិប្រជាធិបតេយ្យរូបណីយកម្ម នៃ ជីវិតភាពនយោបាយ ពិតប្រាកដ នៅស្រុកខ្មែរ។ ហើយ ការដែលពិបាកនឹងធ្វើ គឺ វាមិនអាចនឹងបញ្ចូលគំនិតនេះ ទៅក្នុងសតិ នៃពួកអ្នកដឹកនាំផ្តាច់ការ បានជាដាច់ខាត ក្រៅពី ប្រជាពលរដ្ឋ នាំគ្នាងើបប្រឆាំង ដើម្បី រំលំរបបផ្តាច់ការ។ ការណ៍នេះ វាជា កំណត់ការចងចាំ មានចារនៅក្នុងប្រវត្តិសាស្ត្រ នៃមនុស្សជាតិ។ ដូច្នេះ ការលើកយក អំពើព្រៃផ្សៃគ្រប់បែបយ៉ាង មកបន្ទោស ពីសំណាក់ពួកអ្នកដឹកនាំសព្វថ្ងៃ ដែលសុទ្ធជាអតីតខ្មែរក្រហម មានអតីតកាលមិនច្បាស់ គឺ វាគ្រាន់តែជា ការបញ្ឆោត តន្តី (classique) ដល់ប្រជាពលរដ្ឋខ្មែរ ព្រោះ ខ្លឹមសារ នៃរបៀបដឹកនាំសព្វថ្ងៃ និង អង្គការលើ វា គ្មានអ្វីខុសគ្នាឡើយ, គឺ ទុកអ្នកប្រឆាំងខ្លួនជាសត្រូវ ហើយ សត្រូវត្រូវតែស្លាប់, ទុកប្រជាពលរដ្ឋខ្មែរជាឧបករណ៍ នៃអំណាច ហើយ សេរីភាព នៃពលរដ្ឋ ត្រូវតែលុបចោល, ទុកប្រជាជាតិខ្មែរជាទំនិញ ហើយ ទំនិញត្រូវតែលក់ថោកៗឲចិន-យួន, ទុកអាជ្ញាធរ ជាកម្លាំង ហើយ បាតុកម្ម ត្រូវតែកំទេច ដោយកម្លាំង។ ដូច្នេះ សតិ នៃ ថ្ងៃទី ១៧ មេសា ឆ្នាំ ១៩៧៥ របស់របបដឹកនាំសព្វថ្ងៃ វាគ្មាន សារជាតិ ជា ករណីយកិច្ច នៃកំណត់ការចងចាំ នោះឡើយ តែផ្ទុយទៅវិញ វាជាគំរូ នៃគោលវិធី នៃការដឹកនាំ៕